**ឯកសារស្រាវជ្រាវ**

**ស្តីពី**

# “ការលើកកម្ពស់ការចូលរួមរបស់ស្ត្រីនៅក្នុងឆាកនយោបាយនៅថ្នាក់ក្រោមជាតិ”

*ខែមីនា ឆ្នាំ២០១៣*

**វិទ្យាស្ថានសភាកម្ពុជា**

# មាតិកា


I- សេចក្តីផ្តើម ........ 1
II- សារៈសំខាន់នៃកំណែទម្រង់វិមជ្ឈការដើម្បីលើកកម្ពស់ការចូលរួមរបស់ស្ត្រីនៅក្នុងនយោបាយ ........ 2
III- បទពិសោធន៏ពីបណ្តាប្រទេសនានាទាក់ទងនឹងការលើកកម្ពស់ស្ត្រីក្នុងវិស័យនយោបាយតាមរយៈកំណែទម្រង់ វិមជ្ឈការ 3
IV- ក្របខណ្ឌច្បាប់ និងគោលនយោបាយ ........ 4
V- ការលើកកម្ពស់តួនាទីរបស់ស្ត្រីតាមរយៈច្បាប់វិមជ្ឈការ ........ 6
VI- ភាពជោគជ័យនៃកំណែទម្រង់វិមជ្ឈការដើម្បីលើកស្ទួយតួនាទីស្ត្រីនៅក្នុងឆាកនយោបាយ ........ 8
VI. ឧបសគ្គធំៗដែលរារាំងដល់ការចូលរួមរបស់ស្ត្រីក្នុងឆាកនយោបាយ
១- អាទិភាពរបស់គណបក្សនយោបាយ ........ 9
២- កត្តាសង្គម និងកង្វះខាតការគាំទ្រ ........ 10
៣- ការអប់រំ ........ 11
៤- ភាពឯករាជ្យខាងសេដ្ឋកិច្ច ........ 12
៥- ការអនុវត្តគោលនយោបាយ
៦- ការបញ្ចេញទស្សនៈក្នុងការធ្វើសម្រេចចិត្តនៅថ្នាក់មូលដ្ឋាន ........ 13
VIII- តួនាទីសមាជិកសភាក្នុងការពង្រឹងតួនាទីស្ត្រីក្នុងការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ ........ 14
IX- សេចក្តីសន្និដ្ឋាន ........ 15
X. បញ្ហាប្រឈមសម្រាប់ការពិចារណានាពេលខាងមុខ
បញ្ជីឯកសារយោង ........ 19
បទសម្ភាសន៍ ........ 21
ឧបសម្ព័ន្ធ ........ 22

**វិទ្យាស្ថានសភាកម្ពុជា**

**ឯកសារស្រាវជ្រាវ**

**"ការលើកកម្ពស់ការចូលរួមរបស់ស្ត្រីនៅក្នុងឆាកនយោបាយនៅថ្នាក់ក្រោមជាតិ"**

## I- សេចក្តីផ្តើម

នៅប្រទេសកម្ពុជា ស្ត្រីចូលរួមចំនែកយ៉ាងសំខាន់ និងមើលឃើញនៅក្នុងការអភិវឌ្ឍនយោបាយ សេដ្ឋកិច្ច និង សង្គម។ ការរួមចំនែកទាំងនេះគឺជាការចូលរួមយ៉ាងសំខាន់សម្រាប់សុខមាលភាពគ្រួសារ និងសហគមន៍ ជាពិសេសក្នុងការអភិវឌ្ឍប្រទេសជាតិទាំងមូល ។ នៅក្នុងគ្រួសារភាគច្រើនស្ត្រីគឺជាអ្នកទទួលខុសត្រូវលើ ផ្នែកអាហារូបត្ថម្ភ ការអប់រំ និងការការពារសុខភាពរបស់សមាជិកក្រុមគ្រួសារ និងសហគមន៍ទាំងមូល ។ ប៉ុន្តែស្ត្រីតែងតែទទួលបាននូវការអប់រំ ការថែរក្សាសុខភាព ឱកាសការងារ និងប្រកបអាជីវកម្មតិចតួចបើធៀបទៅនឹងបុរស[1]។ ជាប្រពៃណី ស្ត្រីមានតួនាទីតិចជាងបុរសនៅក្នុងឆាកនយោបាយ ដែលនេះ ជាការរាំងមួយក្នុងការចូលរួមអោយបានសកម្មនៅក្នុងការសម្រេចចិត្តដែលពាក់ព័ន្ធដល់សុខមាលភាព និងការ រស់នៅរបស់ ពួកគេ ។ មានមនុស្សជាច្រើន ដែលមានគំនិតសុទិដ្ឋិនិយមអំពីការកើនឡើង នូវការចូលរួមរបស់ស្ត្រី ព្រោះគេបានគិតថា មានស្ត្រីជាតំណាងនៅក្នុងវិស័យនយោបាយ នឹងកាន់តែនាំមកនូវការអភិវឌ្ឍនៅក្នុងសហគមន៍ គេយល់ថា អ្នកដឹកនាំជាស្ត្រីមានការប្តេជ្ញាចិត្តខ្ពស់ និងចូលរួមនៅក្នុងសហគមន៍សកម្មជាងបុរស ស្ត្រីមានភាពជាអ្នកដឹកនាំខ្ពស់ក្នុងការទំនាក់ទំនងជាមួយប្រជាពលរដ្ឋនៅក្នុងសហគមន៍ទាំងក្នុងកិច្ចការសង្គម និង សេដ្ឋកិច្ច[2]។ ការចូលរួម និងការដឹកនាំរបស់ស្ត្រី អាចជួយដល់ការងារលើកកម្ពស់កំរិតជីវភាពរបស់ប្រជាជនខ្មែរទាំងមូល និងសម្រេចបាននូវគោលដៅអភិវឌ្ឍសហសវត្សរបស់កម្ពុជា ដែលក្នុងនោះគោលដៅ ទី៣ស្តីពីៈ ការលើកកម្ពស់សមភាពយេនឌ័រ និងការផ្តល់អំណាចដល់ស្ត្រី ។

ការជម្រុញអោយមានការចូលរួមរបស់ស្ត្រីនៅក្នុងការធ្វើសេចក្តីសម្រេចចិត្ត នៅតែជាបញ្ហាប្រឈមដែលត្រូវដោះស្រាយ ដូចជា បញ្ហាជំនឿ ដែលចាត់ទុកថាស្ត្រី មិនសក្តិសមនឹងតំណែងធំៗ ឬចូលរួមនៅក្នុងសេចក្តីសម្រេចចិត្ត។ ស្ត្រីត្រូវទទួលបន្ទុកបន្ថែម ជាអ្នកមើលថែទាំ និងទទួលខុសត្រូវការងារផ្ទះសម្បែង ដែលទាំងនេះនៅតែជា បញ្ហាចំបង ដែលរាំងស្ត្រី ក្នុងការចូលរួមក្នុងឆាកនយោបាយ ។ ឯកសារនេះ នឹងបង្ហាញពីកត្តាមួយចំនួន ដែលជា កង្វះខាតបទពិសោធន៍ ក្នុងភាពជាអ្នកដឹកនាំ និងគ្រប់គ្រង នៅក្នុងវិស័យនយោបាយ និង មុខងារ សាធារ ណៈ[3] ។

---

[1] Lara Grisffith (2010), Strengthening Democracy and Electoral Process in Cambodia. UNDP Cambodia

[2] Kim & Ojendal (2012) 'A Gendered Analysis Of Decentralization Reform in Cambodia' CDRI, Phnom Penh

[3] Ministry of Women's Affairs 2009. *Neary Rattanak III*, Five Year Strategic Plan 2009-2013.

II- សារៈសំខាន់នៃកំណែទម្រង់វិមជ្ឈការ ដើម្បីលើកកម្ពស់ ការចូលរួមរបស់ស្ត្រី នៅក្នុងនយោបាយ

កំណែទម្រង់វិមជ្ឈការ ផ្សារភ្ជាប់យ៉ាងជិតស្និទ្ធិទៅនឹងនយោបាយ ហើយដែលអំណាចនៅក្នុងសង្គម ត្រូវបានរៀបចំឡើងវិញ ដោយផ្លាស់ប្តូរពីការធ្វើផែនការ និងការអនុវត្តសេចក្តីសម្រេចចិត្ត និងការផ្តល់សេវាពីថ្នាក់លើចុះមកថ្នាក់ក្រោម និងពីថ្នាក់ក្រោមទៅថ្នាក់លើវិញ ដែលសង្កត់ធ្ងន់អំពីការផ្តល់ អំណាចដល់រាល់ការសម្រេចចិត្តដែលពាក់ព័ន្ធនឹងជីវភាពរបស់ពួកគេ ។ តាមរយៈកំណែទម្រង់នេះ ស្ត្រីអាចបញ្ចេញនូវមតិ និងទស្សនៈរបស់ខ្លួន ក្នុងការជជែកវែកញែកអំពីបញ្ហានៅក្នុងសហគមន៏របស់ខ្លួន ដែលជួយជំរុញអោយហេដ្ឋារចនាសម្ព័ន្ធ កាន់តែប្រសើរឡើង យល់ដឹងពីប្រជាធិបតេយ្យអោយកាន់តែស៊ីជម្រៅ និងលើកស្ទួយការផ្តល់សេវា កំណែទម្រង់ នេះក៏បង្ហាញអំពីសមភាពយេនឌ័រនៅក្នុងវិស័យនយោបាយ និងលើកកម្ពស់ភាពស្មើគ្នានៅក្នុងការធ្វើសេចក្តីសម្រេចនៅថ្នាក់មូលដ្ឋានរវាងបុរស និងស្ត្រី[4]។ ក្រៅពីការផ្លាស់ប្តូរទាំងនេះ ការអនុវត្ត ផ្សេងៗ ដែលទាក់ទងនឹងអភិបាលកិច្ច និងវប្បធម៌ ក៏អាចជាបញ្ហាដែលចាក់ឬសជ្រៅ និងមានផលលំបាកក្នុងការផ្លាស់ប្តូរ ព្រោះត្រូវប្រឈមនឹងកត្តាប្រពៃណី ទំនៀមទម្លាប់ និងការរៀបចំខ្លួន ដើម្បីប្រឡូកក្នុងឆាកនយោបាយ ។ ទោះបីជាស្ត្រីនៅថ្នាក់មូលដ្ឋានមានសកម្មភាពខ្លាំងក្លានៅក្នុងកិច្ចការសេដ្ឋកិច្ចដែលមានទំហំតូច និងនៅក្នុងគ្រួសារក៏ដោយ ក៏ទស្សនៈដែលយល់ថាតួនាទីផ្នែកនយោបាយសក្តិសមសម្រាប់តែបុរសនោះ នៅតែបន្តរហូត[5] ។

> នៅក្នុងការលើកឡើងរបស់ សេចក្តីប្រកាសទូទាំងសកលលោករបស់IULA (International Union of Local Authority) ស្តីពីស្ត្រីនៅក្នុងរដ្ឋបាលមូលដ្ឋានៈ
>
> *រដ្ឋបាលថ្នាក់ក្រោមជាតិមានតួនាទីពិសេសមួយក្នុងការរួមចំនែកក្នុងការខិតខំប្រឹងប្រែងជាសកលដើម្បីសមភាពយេនឌ័រ និងធ្វើអោយមានការផ្លាស់ប្តូរដ៏ធំមួយចំពោះស្ថានភាពរបស់ស្ត្រី និងសមភាពយេនឌ័រនៅក្នុងពិភពលោក ក្នុងសមត្ថភាពដែលស្ថិតក្នុងតំណែងគ្រប់គ្រងដែលមានទំនាក់ទំនងយ៉ាងជិតស្និទ្ធបំផុតជាមួយប្រជាពលរដ្ឋ[6]។*

ភាពជោគជ័យរបស់វិមជ្ឈការប្រជាធិបតេយ្យ អាចនឹងត្រូវបានមើលឃើញតាមរយៈ ការចូលរួមពីពីអ្នកដែលពាក់ព័ន្ធទាំងអស់នៅក្នុងការសម្រេចចិត្ត និងក្នុងឆាកនយោបាយ ដែលចាត់ទុកថា វត្តមានរបស់ស្ត្រី គឺជាភាពចាំបាច់នៅក្នុងដំណើរការទាំងនេះ ។ យោងទៅតាមរបាយការណ៏ស្ថានភាពឆ្នាំ២០១០ របស់ UNDP បាន

---

[4] Kim and Ojendal (2012)
[5] Frieson 2001, cited in Kim and Ojendal (2012)
[6] Byrne and Spencer 2005, cited in Kim and Ojendal (2012)

អោយដឹងថា រដ្ឋបាលថ្នាក់ក្រោមជាតិ គឺជាធាតុនយោបាយដ៏សំខាន់បំផុតរបស់ប្រជាជនក្រីក្រជាងគេ ដែលនៅក្នុងតំបន់ និងមានតួនាទីយ៉ាងសំខាន់ផងដែរ ក្នុងការជម្រុញការចូលរួមរបស់ស្ត្រីក្នុងផ្នែកនយោបាយ ។ ប៉ុន្តែ វិមជ្ឈការមិនបាននាំអោយការចូលរួមរបស់ស្ត្រីកើនឡើងដោយស្វ័យប្រវត្តិនោះទេ នៅមានបញ្ហាដែលកើតមានជាយូរមកហើយដែលត្រូវដោះស្រាយប្រសិនបើស្ត្រីត្រូវចូលរួម និងមានសម្លេងប្រកបដោយប្រសិទ្ធភាពនៅក្នុងការធ្វើសេចក្តីសម្រេចចិត្តនៅថ្នាក់មូលដ្ឋាន ។

III- បទពិសោធន៍ពីបណ្តាប្រទេសនានាទាក់ទងនឹងការលើកកម្ពស់ស្ត្រីក្នុងវិស័យនយោបាយតាមរយៈកំណែទម្រង់ វិមជ្ឈការ

យើងសង្កេតឃើញថា នៅក្នុងតំបន់អាស៊ី-ប៉ាស៊ីហ្វិចនេះ ស្ត្រីដែលធ្វើការនៅថ្នាក់ជាតិ ក្នុងតំបន់ បានឈានទៅដល់កំរិតខ្ពស់នៃភាពជាអ្នកដឹកនាំ ប៉ុន្តែ នៅមានកិច្ចការជាច្រើនទៀត ដែលត្រូវធ្វើ ដើម្បីជម្រុញតំណាងជាស្ត្រីនៅក្នុងតួនាទីសម្រេចចិត្តនៅថ្នាក់ក្រោមជាតិ ។ ឧទាហរណ៍ គិតត្រឹមឆ្នាំ២០១០ ចំនួនស្ត្រីជាតំណាងនៅក្នុងតំ ណែងសំខាន់ៗ នៅក្នុងរដ្ឋបាលថ្នាក់ក្រោមជាតិ ថ្នាក់ខេត្ត ថ្នាក់តំបន់[7] (រូបភាព១) មានត្រឹមតែ ៣៧% នៅ ប្រទេសឥណ្ឌា ៣០%ប្រទេសអាហ្វហ្គានីស្ថាន ២៩.៤%ប្រទេសញូសឺឡែន ២៧.៨% ប្រ ទេសអូស្ត្រាលី និង ២៣.៨%ប្រទេសវៀតណាម ។ នៅកម្រិតរដ្ឋបាលទាបជាងនេះ តួលេខស្ត្រីក៏មានចំនួនទាបដែរ គឺ ១៥% ប្រទេសអាហ្វហ្គានីស្ថាន ១៩.៨%ប្រទេសហ្វីលីពីន និង១៦%ប្រទេសញូសឺឡែន[8] (មើលឧបសម្ព័ន្ធ រូប ភាព២)។

លទ្ធផលដែលទទួលបានពីវិមជ្ឈការក្នុងការផ្តល់អំណាចដល់ស្ត្រីបានមកពីបរិយាកាសនយោបាយរបស់ប្រទេស និងទំនាក់ទំនងរវាងអ្នកពាក់ព័ន្ធនានានៅថ្នាក់មូលដ្ឋាន ។ នៅក្នុងប្រទេសកម្ពុជា ទោះបីជាការចូលរួមរបស់ស្ត្រីមានការកើនឡើងគួរអោយកត់សម្គាល់នៅគ្រប់កំរិត និង ស្ថាប័នរដ្ឋាភិបាល រួមទាំងព្រឹទ្ធសភា រដ្ឋសភា ថ្នាក់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងក្រុមប្រឹក្សាឃុំ/សង្កាត់ និងក្រុមប្រឹក្សាភិបាលក៏ដោយ ក៏តំណាងជាស្ត្រីនៅក្នុងផ្នែកប្រតិបត្តិរបស់រដ្ឋាភិបាល នៅមានកំរិតទាបនៅឡើយ ។ នៅឆ្នាំ២០០៨ សម្តេចនាយករដ្ឋមន្ត្រីបានផ្តួចផ្តើមនូវគោលនយោបាយសកម្មភាព ដើម្បីតែងតាំងស្ត្រីជា អភិបាលខេត្តរងនៅគ្រប់ខេត្ត និងស្រុក ។ បច្ចុប្បន្ននេះ យើងមិនទាន់មានស្ត្រីជាអភិបាលខេត្តនៅឡើយទេ ប៉ុន្តែយើងមាន២០% នៃអភិបាលខេត្តរង និង ២៩% នៃអភិបាលស្រុករងគឺជា ស្ត្រី[9]។

---

[7] UNDP Women in Local government in Asia Pacific Status Report (2010)

[8] Ibid.

[9] Ministry of Women's Affairs, July 2012, Women's Political Participation in Cambodia : Policy/mechanism, Progress and lesson learnt

ចំនួនស្ត្រីដែលនៅក្នុងឃុំ ដែលជាថ្នាក់ទាបបំផុតរបស់អាជ្ញាធរថ្នាក់ក្រោមជាតិមានការកើនឡើង តែចំនួនសរុបនៅតែមានកំរិតទាបនៅឡើយ ។ នៅក្នុងអាណត្តិដំបូងនៃការបោះឆ្នោតឃុំ-សង្កាត់នៅឆ្នាំ២០០២ ភាគរយស្ត្រីនៅក្នុងក្រុមប្រឹក្សាឃុំមានចំនួន៩.៤% និង១៥.១%នៅអាណត្តិទី២ ។ ការធ្វើសមាហរណកម្មគោលនយោបាយកម្ពុជា ស្តីពីការអភិវឌ្ឍប្រជាធិបតេយ្យថ្នាក់ក្រោមជាតិ និងការចូលរួមការពិនិត្យមើលឡើងវិញ នូវគ្រប់រូបភាពនៃការគ្រប់គ្រង ថ្នាក់ក្រោមជាតិ ធ្វើអោយចំនួនស្ត្រីមានការកើនឡើងដល់១៧.៧%នៅក្នុងអាណត្តិទី៣[10] (រូបភាព៣) ។ ទោះជាយ៉ាងណាក៏ដោយ យើងគួរចងចាំថា មិនមានតំណាងស្ត្រីគ្រប់គ្រាន់ នៅក្នុងតំណែងធ្វើការសម្រេចចិត្តថ្នាក់ខ្ពស់ នៅក្នុងថ្នាក់ជាតិ និងនៅក្នុងរដ្ឋបាលថ្នាក់ខេត្ត និងស្រុកទេ[11] ។ ទោះបីជាការចូលរួមរបស់ស្ត្រីនៅក្នុងគ្រប់កំរិតនៃការសម្រេចចិត្តមានការកើនឡើងក៏ដោយ ក៏ភាពជាអ្នកដឹកនាំនៅកម្ពុជានៅតែជាបុរស ។ នៅតែមានចម្ងល់ជាច្រើនទាក់ទងនឹងការចូលរួមរបស់ស្ត្រីនៅថ្នាក់ក្រោមជាតិ ដូចជា តើស្ត្រីនៅក្នុងអំណាចនយោបាយអាចធ្វើអ្វីបានខ្លះដើម្បីជួយអភិវឌ្ឍន៍មូលដ្ឋានអោយប្រសើរឡើង ជាពិសេសលើបញ្ហាស្ត្រី និងកុមារ? តើស្ត្រីដែលកាន់អំណាចជួបបញ្ហាអ្វីខ្លះដែលធ្វើអោយប៉ះពាល់ដល់ការងាររបស់គាត់? និងតើអ្វីខ្លះដែលគួរធ្វើដើម្បីលើកកម្ពស់តួនាទីរបស់ពួកគេ?

## IV- ក្របខណ្ឌច្បាប់ និងគោលនយោបាយ

រាជរដ្ឋាភិបាលកម្ពុជា បានកំណត់ការផ្តល់អំណាចដល់ស្ត្រីជាទិសដៅអាទិភាព នៅគ្រប់កំរិតនៅទូទាំងប្រទេស ជាពិសេស តាមតំបន់ជនបទ ដើម្បីលើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាជន និងជម្រុញស្ត្រីអោយចូលរួមធ្វើការសម្រេច ចិត្តអោយបានច្រើន។ ច្បាប់ជាច្រើនត្រូវបានបង្កើតឡើង និងអនុម័ត ដើម្បីសម្រេចអោយបាននូវសមភាពយេនឌ័រ ផ្តល់ សិទ្ធិអំណាចដល់ស្ត្រី និងធ្វើអោយប្រាកដថា សិទ្ធិ សេរីភាព និងសុខមាលភាពរបស់ពួកគេត្រូវបានការពារ។

សមភាព និងការយកចិត្តទុកដាក់ដល់បញ្ហាយេនឌ័រ ត្រូវបានដាក់បញ្ចូលទៅក្នុងច្បាប់ និងគោលនយោបាយរួមមាន៖

- រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣ បានចែងថា "បុរស និងស្ត្រីមានសិទ្ធិស្មើគ្នា រួមបញ្ចូលទាំងសិទ្ធិមនុស្ស និងរាល់ទិដ្ឋភាពនៃសេដ្ឋកិច្ចសង្គម វប្បធម៌ និងការចូលរួមដ៏សកម្មនៅក្នុងជីវភាពនយោបាយរបស់ប្រជាជនកម្ពុជា" ។
- យុទ្ធសាស្ត្រចតុកោណសម្រាប់ការអភិវឌ្ឍរបស់រាជរដ្ឋាភិបាល ការផ្តល់អំណាច សមធម៌ និងប្រសិទ្ធភាព ដំណាក់កាលទី២ (២០០៩-២០១៣) បានកំនត់ថា "ស្ត្រី គឺជាឆ្អឹងខ្នងនៃសេដ្ឋកិច្ច

[10] NEC Updated, 2012

[11] Ministry of Women's Affairs (2012), Women's Political Participation in Cambodia: Policy/mechanism, Progress and lesson learnt

និងសង្គម" និងទទួលស្គាល់នូវការភ្ជាប់ទំនាក់ទំនងរវាងសមភាពយេនឌ័រ តួនាទីរបស់ស្ត្រី ការកាត់បន្ថយភាពក្រីក្រ និងការអភិវឌ្ឍសេដ្ឋកិច្ចសង្គមរបស់ប្រទេសជាតិ ។ ជ្រុងអាទិភាពទីបួន គឺការបង្កើនសមត្ថភាព និងការអភិវឌ្ឍធនធានមនុស្ស។ ជ្រុងអាទិភាពនេះ បានចែកចេញជាបួនមុំអភិវឌ្ឍន៍ដែលរួមមាន ការឆ្លុះបញ្ចាំងអំពីជំហររបស់រាជរដ្ឋាភិបាលលើសមភាពយេនឌ័រ និងការផ្តល់អំណាចដល់ស្ត្រី លើគ្រប់វិស័យដូចជា ការពង្រឹងគុណភាពអប់រំ សេវាសុខភាព ការអនុវត្តគោលនយោបាយយេនឌ័រ និងការអនុវត្តគោលនយោបាយជាតិប្រជាជន[12] ។

- ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ(២០០៦-២០១០) និងការធ្វើបច្ចុប្បន្នភាពសម្រាប់ឆ្នាំ (២០០៩-២០១៣)។ ផែនការនេះសង្កត់ធ្ងន់ពីសារៈសំខាន់ក្នុងការអនុវត្តគោលនយោបាយ និងការបញ្ជ្រាបយេនឌ័រ ។ បន្ថែមពីលើការផ្តល់អោយនូវឱកាសការងារ លើកកម្ពស់ការអប់រំ និងការបណ្តុះបណ្តាលជំនាញ ដល់ស្ត្រី និងការការពារសិទ្ធិរបស់ស្ត្រីនៅក្នុងការងារ ការងារចំបងរបស់រាជរដ្ឋាភិបាលកម្ពុជា គឺការពង្រឹងតួនាទី និងសមត្ថភាពស្ត្រី នៅក្នុងនយោបាយ និងការសម្រេចចិត្ត ដោយបង្កើននូវអនុបាត របស់ស្ត្រីនៅគ្រប់លំដាប់ថ្នាក់នៃរដ្ឋាភិបាល និងធ្វើការតស៊ូមតិនៅគ្រប់កម្រិតទូទាំងប្រទេស[13] ។
- ផែនការយុទ្ធសាស្ត្ររយៈពេល៥ឆ្នាំ(២០០៩-២០១៣) ដែលធ្វើដោយក្រសួងកិច្ចការនារី ឈ្មោះថា នារីរតនៈ៣ ។ ផែនការយុទ្ធសាស្ត្រនេះ ផ្តោត សំខាន់ ទៅលើចំនុច ជាយុទ្ធ សាស្ត្រ ចំនួន០៥ រួមមានការលើកកម្ពស់ស្ត្រីនៅក្នុងភាពជាអ្នកដឹកនាំ និងការសម្រេចចិត្ត ព្រមជាមួយ នឹងកម្មវិធីបញ្ជ្រាបយេនឌ័រសម្រាប់គោលនយោបាយជាតិ កម្មវិធីកំណែទម្រង់ និងវិស័យសេវា និងការធ្វើអន្តរាគមន៍លើបញ្ហាដែលពាក់ព័ន្ធនានា ។

ព្រះរាជាណាចក្រកម្ពុជា គឺជាប្រទេសហត្ថលេខីលើអនុសញ្ញា និងកិច្ចព្រមព្រៀងអន្តរជាតិជាច្រើន។ កិច្ចព្រមព្រៀងទាំងនេះជម្រុញ ដល់រាជរដ្ឋាភិបាលក្នុងការលើកកម្ពស់សម ភាពយេនឌ័រ នៅគ្រប់វិស័យ ទាំងអស់។ អាទិភាពត្រូវបានផ្តល់អោយភាពខុសគ្នាក្នុងការទទួលបានការអប់រំ សុខភាព សេដ្ឋកិច្ច ការការពារតាមផ្លូវច្បាប់ និងការធ្វើសេចក្តីសម្រេចចិត្ត[14] ។ ទាំងនោះរួមមានៈ

- អនុសញ្ញាស្តីពីការលុបបំបាត់ការរើសអើងគ្រប់ទម្រង់ប្រឆាំងនឹងស្ត្រីលើគ្រប់រូបភាព (CEDAW) ឆ្នាំ១៩៩០
- វេទិកាសកម្មភាពទីក្រុងប៉េកាំង (BPFA) ឆ្នាំ១៩៩៥

[12] Ministry of Women's Affairs (2009). *Neary Rattanak III*, Five Year Strategic Plan 2009-2013.
[13] Ministry of Women's Affairs (2009). *Neary Rattanak III*, Five Year Strategic Plan 2009-2013.
[14] Ministry of Women's Affairs (2008). Cambodia Gender Assessment: "A Fair Share For Women", chapter 7: "Gender disparities in politics and Public decision making"

- សេចក្ដីថ្លែងការណ៍ ស្ដីពីការលុបបំបាត់អំពើហិង្សាទៅលើស្ត្រីនៅក្នុងតំបន់អាស៊ាន ឆ្នាំ២០០៤
- គោលដៅអភិវឌ្ឍន៍សហស្សវត្សកម្ពុជា (CMDGs)។ គោលដៅនេះជម្រុញអោយរាជរដ្ឋាភិបាល លុបបំបាត់អោយបាននូវវិសមភាពយេនឌ័រក្នុងវិស័យការងារនៅក្នុងគ្រប់ជាន់ថ្នាក់ បង្កើនការចូលរួមរបស់ស្ត្រីក្នុងការធ្វើសេចក្ដីសម្រេចចិត្ត និងក្នុងរដ្ឋបាលសាធារណៈ និងលុបបំបាត់អំពើហិង្សាគ្រប់ទម្រង់ទៅលើស្ត្រី[15] ។

V- ការលើកកម្ពស់តួនាទីរបស់ស្ត្រីតាមរយៈច្បាប់វិមជ្ឈការ

តាមរយៈច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលឃុំ-សង្កាត់ឆ្នាំ២០០១ រាជរដ្ឋាភិបាលកម្ពុជា បានបង្កើតមូលដ្ឋានកំរិតឃុំ ព្រោះនេះជាចំនុចសំខាន់ក្នុងការអភិវឌ្ឍប្រជាធិបតេយ្យ ។ ច្បាប់នេះបង្កើតឡើងដើម្បីផ្ដល់ឱកាសអោយសមាជិកក្រុមប្រឹក្សាជាស្ត្រី ធ្វើការងារលើបញ្ហាស្ត្រី និងកុមារ ។ ក្រុមប្រឹក្សាឃុំ-សង្កាត់ត្រូវជ្រើសរើសស្ត្រីដើម្បីធ្វើជាប្រធាន និងអនុប្រធានភូមិ ។ ក្របខ័ណ្ឌយុទ្ធសាស្ត្រសម្រាប់វិមជ្ឈការ និងសហវិម្សការឆ្នាំ២០០៥ បង្ហាញពីការអនុវត្ត ដំណាក់កាលទី២នៃកំណែទម្រង់វិមជ្ឈការ និងសហវិមជ្ឈការ ដែលត្រូវបានអនុវត្តឡើងតាមរយៈច្បាប់រៀបចំអង្គការឆ្នាំ២០០៨ ដែលផ្ដល់អោយនូវការបោះឆ្នោតអសកលឬមិនផ្ទាល់ ចំពោះថ្នាក់ស្រុក/ខណ្ឌ និងខេត្ត/ក្រុង ។ ក្របខ័ណ្ឌ យុទ្ធសាស្ត្រនេះបង្ហាញពីសារៈសំខាន់នៃការយកចិត្តទុកដាក់លើបញ្ហាយេនឌ័រ ព្រោះបានកំនត់ថា "កំណែទម្រង់នេះនឹងបង្កើតឡើងនូវប្រព័ន្ធ និងនីតិវិធី ដើម្បីធ្វើអោយប្រាកដថាប្រជាពលរដ្ឋទាំងអស់ ជាពិសេសស្ត្រី ក្រុមងាយ រងគ្រោះ និងជនជាតិភាគតិច មានឱកាសចូលរួមក្នុងការសម្រេចចិត្តនៅថ្នាក់រាជធានី/ខេត្ត និង ក្រុង/ស្រុក/ខណ្ឌ និងឃុំ-សង្កាត់"[16] ។ មានមាត្រាមួយចំនួននៅក្នុងច្បាប់រៀបចំអង្គការដែលទាក់ទងនឹងបញ្ហាយេនឌ័រ និងបង្ហាញយ៉ាងច្បាស់ពីគោលការណ៍នៃសមភាពយេនឌ័រ និងសិទ្ធិ និងការផ្ដល់អំណាចដល់ស្ត្រី ។ ច្បាប់នេះគឺជាមូលដ្ឋានក្នុងការលើកកម្ពស់តួនាទី ការចូលរួម និងភាពតំណាងជាស្ត្រីនៅក្នុងនយោបាយ និងសេចក្ដីសម្រេចចិត្តនៅថ្នាក់រាជធានី/ខេត្ត/ក្រុង/ស្រុក/ខណ្ឌ និងឃុំ/សង្កាត់[17] ។

បន្ថែមពីលើនេះទៀត រាជរដ្ឋាភិបាលកម្ពុជាបានបង្កើតកម្មវិធីជាតិរយៈពេល១០ឆ្នាំ សម្រាប់ការអភិវឌ្ឍប្រជាធិបតេយ្យថ្នាក់ក្រោមជាតិ(២០១០-២០១៩) ដើម្បីពង្រឹងតួនាទីស្ត្រី និងសមភាពយេនឌ័រនៅថ្នាក់ក្រោមជាតិ ដោយបានកំនត់ថា ការអភិវឌ្ឍប្រជាធិបតេយ្យថ្នាក់ក្រោមជាតិ មានប្រសិទ្ធភាព និងមានចីរភាពលុះត្រាណាតែបញ្ហាយេនឌ័រត្រូវបានដោះស្រាយ។ ទាំងកម្មវិធីជាតិ និងផែនការអនុវត្តរយៈពេលបីឆ្នាំដំបូង មានបញ្ចូលយុទ្ធសាស្ត្រយេនឌ័រជាមួយនឹងគោលដៅរួម គឺការទទួលបាននូវរដ្ឋបាលថ្នាក់ក្រោមជាតិ ដែលយកចិត្តទុកដាក់

[15] Ministry of Planning (2005) 'Achieving the Cambodia Millennium Development Goals Update; Royal Government of Cambodia.
[16] National Program for Sub-National Democratic Development (NP-SNDD) 2010-2019
[17] National Program for NSDD 2010-2019, Annex 2, Gender Mainstreaming for Sub-national Administrations

ពីបញ្ហាយេនឌ័រ ក៏ដូចជាការអភិវឌ្ឍថ្នាក់ក្រោមជាតិដែលលើកកម្ពស់សមភាពយេនឌ័រ និងការផ្តល់អំណាចដល់ស្ត្រីក្នុងរាល់រូបភាពនៅក្នុងដំណើរការអភិវឌ្ឍប្រជាធិបតេយ្យថ្នាក់ក្រោមជាតិ[18]។

យើងអាចនិយាយបានថា ការបញ្រ្ជាបយេនឌ័រជាដំណើរការនៃការវាយតម្លៃពីការអនុវត្តសកម្មភាពរវាងបុរសនិងស្ត្រីក្នុងការចូលរួមរៀបចំផែនការសកម្មភាពណាមួយ ដូចជា ការតាក់តែងច្បាប់ គោលនយោបាយ កម្មវិធីនៅគ្រប់វិស័យ និងគ្រប់កំរិត ។ នេះក៏ជាយុទ្ធសាស្រ្តមួយសម្រាប់ការដាក់បញ្ចូលគ្នានូវបទពិសោធន៍ និងការព្រួយ បារម្ភរបស់បុរសនិងស្ត្រីដើម្បីអោយការរៀបចំ ការអនុវត្ត ការតាមដាន និងវាយតម្លៃនៃគោលនយោបាយ និងកម្មវិធីនានាទាក់ទងនឹងកិច្ចការនយោបាយ សេដ្ឋកិច្ច និងសង្គមមានលក្ខណៈគ្រប់គ្រាន់ ។ ការធ្វើ បែបនេះនឹងបង្កលក្ខណៈអោយស្ត្រី និងបុរសទទួលបាននូវផលប្រយោជន៍ស្មើគ្នា ហើយវិសមភាពក៏នឹងត្រូវ កាត់បន្ថយទៅតាមនោះដែរ ។ ជារួមគោលដៅធំបំផុតនៃការបញ្រ្ជាបយេនឌ័រ គឺដើម្បីសម្រេចបាននូវសម ភាពយេនឌ័រ[19] ។

នៅ ថ្នាក់ក្រោមជាតិ មន្ទីរកិច្ចការនារីខេត្តគឺជាតំណាងអោយគណៈកម្មាធិការអភិវឌ្ឍន៍ជនបទខេត្ត ក៏ដូច ជាគណៈកម្មាធិការប្រតិបត្តិ ដែលមានភារកិច្ចផ្តល់ការគាំទ្រដល់ការបញ្រ្ជាបយេនឌ័រ នៅក្នុងខេត្តរបស់ ខ្លួន ។ ជនបង្គោលផ្នែកយេនឌ័រត្រូវបានបង្កើតឡើងនៅតាមមន្ទីរខេត្តនានា[20] ។ គណៈកម្មាធិការពិគ្រោះយោបល់លើបញ្ហាស្ត្រី និង កុមារត្រូវបានបង្កើតឡើងជាយន្តការថ្នាក់ក្រោមជាតិមួយដើម្បីជួយជម្រុញការលើកកម្ពស់សមភាពយេនឌ័រ និងផ្តល់ អំណាចដល់ស្ត្រីនិងកុមារ ។ គណៈកម្មាធិការពិគ្រោះយោបល់ លើបញ្ហាស្ត្រីនិងកុមារ អនុវត្តតួនាទី ដ៏សំខាន់ក្នុង ការផ្តល់ជាសំណូមពរ និងអនុសាសន៍ផ្សេងៗដល់ក្រុមប្រឹក្សាឃុំ គណៈអភិបាលខេត្ត អភិបាល និងគណៈកម្មា ធិការផ្សេងៗទៀត លើបញ្ហាដែលពាក់ព័ន្ធនឹងសមភាពយេនឌ័រ និងបញ្ហាស្ត្រី និងកុមារដែលស្ថិតក្នុងដែនសមត្ថកិច្ច មុខងារ និងតួនាទីរបស់ក្រុមប្រឹក្សា[21] ។

ការបញ្រ្ជាបយេនឌ័រនៅក្នុងកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការកើតឡើងតាមរយៈ ការអនុវត្តតាមកម្មវិធីសីឡានៅថ្នាក់ឃុំ-សង្កាត់ និង ខេត្ត[22] ដូចខាងក្រោមៈ

- កិច្ចសហការជាមួយក្រសួងពាក់ព័ន្ធ ដើម្បីបញ្រ្ជាបយេនឌ័រទៅក្នុងសេចក្តី ណែនាំ និងគោលន យោបាយអភិវឌ្ឍន៍មូលដ្ឋាន ។

---

[18] Information obtained through interview with NCDD advisor Ms. Henny Anderson and Mary Sok, 14th December 2012
[19] United Nation Economic and Social Council (ECOSOC), 1997. Available at: http://www1.aucegypt.edu/src/engendering/definitions.html#Gender%20Mainstreaming
[20] National Program for NSDD 2010-2019, Annex 2, Gender Mainstreaming for Sub-national Administrations
[21] Ministry of Women's Affairs, July 2012, Women's Political Participation in Cambodia : Policy/mechanism, Progress and lesson learnt

-កិច្ចសហការ និងការតស៊ូមតិជាមួយនឹងថ្នាក់រាជធានី/ខេត្ត ស្រុក និងឃុំ ដើម្បីបញ្ជ្រាបយេនឌ័រ នៅក្នុង សេចក្តីណែនាំ និងគោលនយោបាយនានា ។

- ការពង្រឹងសមត្ថភាពដល់មន្ទីរខេត្តទាំងអស់ដើម្បីអនុវត្ត តាមដាន និងវាយតម្លៃការបញ្ជ្រាបយេនឌ័រ ។

-ការបង្កើតអោយមានបណ្តាញយេនឌ័រជាមួយនឹងស្ថាប័ននានានៅតាមមូលដ្ឋានដែលមានការគាំទ្រពី គណបក្សនយោបាយនានា និងក្រសួងមហាផ្ទៃ ដើម្បីបង្កើនមុខតំណែងអភិបាល ក៏ដូចជា អភិបាលរង អភិបាលខ័ណ្ឌ ចៅសង្កាត់ និងមេឃុំជាស្ត្រី អោយបានកាន់តែ មានចំនួនច្រើននិងទូលំទូលាយ ។

- ការរៀបចំអោយមានបេក្ខនារីឈរឈ្មោះសម្រាប់ការបោះឆ្នោតឃុំ-សង្កាត់នា ឆ្នាំ២០០៧ ។

- កិច្ចសហការជាមួយភ្នាក់ងារសម្របសម្រួលកម្មវិធីនៅក្នុងកម្មវិធីបណ្តុះបណ្តាលនៃសមាជិកថ្មីជាស្ត្រី ។

## VI- ភាពជោគជ័យនៃកំណែទម្រង់វិមជ្ឈការដើម្បីលើកស្ទួយតួនាទីស្ត្រីនៅក្នុងឆាកនយោបាយ

ទោះបីជានៅមានទស្សនៈពីបុរាណពីតួនាទីរបស់ស្ត្រី និងការចូលរួមក្នុងឆាកនយោបាយក៏ដោយ ក៏មានភស្តុតាង បង្ហាញថាវប្បធម៌មិនមែននៅតែដដែល មិនផ្លាស់ប្តូរនោះទេ ។ ជំនួយអន្តរជាតិ គោលការណ៍ប្រជាធិបតេយ្យ និងការផ្លាស់ប្តូរនានាក្រោយសម័យសង្គ្រាម នឹងធ្វើអោយមានការផ្លាស់ប្តូរទស្សនៈ និងទម្លាប់បុរាណខ្លះៗ[23] ។ លោក Stivens យល់ឃើញថា "ទំនើបភាវូបនីយកម្មនៅអាស៊ីគឺជំណើរការយេនឌ័រ"[24] ។ ភាពជាតំណាង នយោបាយ និងក្នុងតួនាទីធ្វើសេចក្តីសម្រេចចិត្តសម្រាប់ស្ត្រី និងសមភាពយេនឌ័រត្រូវ បានលើកជម្រុញ ដោយអង្គការទទួលជំនួយអន្តរជាតិ ក៏ដូចជាអង្គការក្រៅរដ្ឋាភិបាលនានានៅក្នុងអំឡុងសម័យក្រោយសង្គ្រាម ជាពិសេសនៅតាមជនបទ ។ ការជម្រុញនេះបានបង្កើតអោយមានបរិយាកាសនយោបាយដែលមានភាពបត់ បែនកាន់តែប្រសើរឡើង ប៉ុន្តែការ អភិវឌ្ឍន៍ទាមទារឲ្យស្ត្រីត្រូវដើរតួនាទីជាគន្លឹះដែលនាំអោយ "តម្រូវការ និងឱកាសសម្រាប់ស្ត្រីនៅក្នុងមុខតំណែង ដឹកនាំកាន់តែកើនឡើង"[25] ។

ការចូលរួមរបស់ស្ត្រីនៅគ្រប់កំរិតបានកើនឡើង ហើយបន្ថែមពីមេឃុំ និងប្រធានក្រុមប្រឹក្សាឃុំដែលជាប់ឆ្នោត នោះ បច្ចុប្បន្ននេះ ស្ត្រីចូលរួមយ៉ាងសកម្មនៅក្នុងរដ្ឋាភិបាល និងជាជនបង្គោលសម្រាប់ឃុំ មេភូមិ និងអនុប្រធានភូមិ ជាដើម[26] ។ ស្ត្រីត្រូវបានគេមើលឃើញថាមានការយល់ដឹង និងភាពជឿជាក់ខ្ពស់ ក្នុងការលើកឡើងពីតម្រូវការ និងកង្វល់នានា ។

[23] Kim and Ojendal (2012)

[24] Stivens (2010), cited in Ojendal and Kim (2012)

[25] Kim and Ojendal (2012)

[26] Ibid.

ស្ត្រីនៅក្នុងឆាកនយោបាយ និងក្នុងមុខតំណែងដឹកនាំនៅថ្នាក់មូលដ្ឋាន ត្រូវបានគេសង្កេតឃើញថាមានការប្តេជ្ញាចិត្តខ្ពស់ក្នុងការដោះស្រាយបញ្ហាសេដ្ឋកិច្ចគ្រួសារ និងកិច្ចការសង្គមរបស់សហគមន៍បានល្អជាងបុរស ។ ស្ត្រីមិនសូវមានភាពលម្អៀងរវាងប្រជាជនដែលមកពីគណបក្សផ្សេងៗ និងមានតម្លាភាពជាង ។ ជាងនេះទៅទៀត វិមជ្ឈការបានផ្តល់ឱកាសដល់ស្ត្រីអោយកាន់តែយល់ដឹងពីសិទ្ធិរបស់ពួកគាត់
និងការចូលរួមនៅក្នុងកម្មវិធីអភិវឌ្ឍន៍ និងការកសាងសមត្ថភាពនានា ។ ការងារទាំងអស់នេះគឺឆ្ពោះទៅរកការបង្កើតនូវតំរូវការសម្រាប់សមភាព និងសកម្មភាពជំនាញនៅក្នុងកិច្ចការសង្គម និងនយោបាយ។ អង្គការក្រៅរដ្ឋាភិបាល និងប្រព័ន្ធផ្សព្វផ្សាយនានាត្រូវបានគេយល់ឃើញថាជាច្រកចេញដ៏សំខាន់ ក្នុងការឈានទៅទិសដៅនៃការពង្រឹងចំណេះដឹងទាក់ទងនឹង យេនឌ័រ ។ ចលករទាំងនេះ គឺបានជួយរុញច្រានក្រុមប្រឹក្សាឃុំទាំងឡាយ និងប្រជាជនមូលដ្ឋានអោយបានយល់ ដឹងអំពី សិទ្ធិនានាទាក់ទងនឹងយេនឌ័រមានដូចជា សមភាពស្ត្រីនៅគ្រប់សកម្មភាព នៅក្នុងជិវិត និងនៅក្នុងវិស័យ ផ្សេងៗ ។ នេះបញ្ជាក់អោយឃើញទស្សនៈពីបុរាណកាន់តែសាបរលាបបន្តិចម្តងៗ និងជួយដល់ស្ត្រីអោយកាន់តែ រឹងមាំ មានការអប់រំ ហើយមានការប្តេជ្ញាចិត្ត ព្រមទាំងអាចទំនាក់ទំនងយ៉ាងមានប្រសិទ្ធភាពជាមួយបណ្តាអង្គការ និងរដ្ឋាភិបាល[27] ។

VII- ឧបសគ្គចំបងដែលរារាំងស្ត្រីក្នុងការចូលរួមយ៉ាងពេញលេញនៅក្នុងនយោបាយឧបសគ្គធំៗដែលរាំងស្ទះដល់ការចូលរួមរបស់ស្ត្រីក្នុងឆាកនយោបាយ

ទោះបីជាមានស្ថិតិបង្ហាញថា ភាពជាតំណាងនៃស្ត្រីនៅតាមមុខតំណែងនានាក្នុងស្ថាប័ននីតិបញ្ញត្តិ និងនីតិប្រតិបត្តិមានការកើនឡើងតាមរយៈការបោះឆ្នោតដោយផ្ទាល់ និងមិនផ្ទាល់ក៏ដោយ[28] ការចូលរួមរបស់ស្ត្រីនៅក្នុងឆាកនយោបាយនៅតែមានកំរិតនៅឡើយ ហើយដំណើរការនៃការសម្រេចចិត្តនៅតែជាប្រឈមយ៉ាងធ្ងន់ធ្ងរក្នុងដំណើរការប្រជាធិបតេយ្យ មានន័យថាស្ត្រីអាចនឹងមិនបានដើរតួនាទីជាតំណាងបានគ្រប់គ្រាន់នៅក្នុងដំណើរ ការនៃការធ្វើការសម្រេចចិត្តនោះទេ ។ មានកត្តាជាច្រើនដែលរាំងស្ទះដល់ការចូលរួម និងឥទ្ធិពលរបស់ស្ត្រីនៅក្នុងឆាកនយោបាយ ។

## ១- អាទិភាពរបស់គណបក្សនយោបាយ

ទោះបីជាស្ត្រីត្រូវបានប្រគល់ភារកិច្ចជាបន្តបន្ទាប់ និងទទួលបានការគោរពផ្តល់តម្លៃនៅក្នុងគណបក្សផ្សេងៗ យ៉ាង ណាក៏ដោយ ក៏ប្រព័ន្ធនៃការបោះឆ្នោតនៅថ្នាក់ឃុំ-សង្កាត់នៅកម្ពុជាត្រូវបានធ្វើតាមរយៈ បញ្ជីបោះឆ្នោតនៃគណបក្សនីមួយៗ។ ស្ត្រីគួរតែត្រូវបានដាក់លេខរៀងនៅខាងលើៗតារាង ដើម្បីទាក់ទាញសន្លឹកឆ្នោត ដើម្បីភ្ជាប់ស្ថានភាព និងការលើកតម្កើងស្ត្រីទៅនឹងដំណើរការរបស់គណបក្សនយោបាយ ។

[27] Ibid.
[28] Ibid.

ការប្តេជ្ញាចិត្តរបស់គណបក្ស គឺជាបុរេល័ក្ខខ័ណ្ឌដែលសំខាន់ជាងគេបំផុតដើម្បីអោយស្ត្រីដើរតួនាទីដ៏សកម្ម នៅក្នុងនយោបាយ ។ កិច្ចការនេះអាចសម្រេចទៅបានតាមរយៈ រយៈពេលនៃការបំរើគណបក្ស ភាពសំខាន់ នៅក្នុងបរិបទ នៃប្រព័ន្ធរៀបចំបញ្ជីគណបក្ស ដែលអនុញ្ញាតិអោយស្ត្រីត្រូវបានដាក់ ជាបេក្ខជនអាទិភាព ដែល ជាគន្លឹះក្នុងការលើក កម្ពស់នយោបាយ[29] ហើយក៏ដូចជាចំពោះ គ្រប់បេក្ខភាពទាំងអស់ដែរ អំណាចនៃការ សម្រេចចិត្តនៅ ក្នុងគណបក្ស អាចអាស្រ័យទៅលើការប្តេជ្ញាចិត្ត និងប្រជាប្រិយភាពពីសំណាក់ប្រជាជន ។ ដូច្នេះ បេក្ខនារីដែលបម្រើការងារ ដើម្បីទទួលបាននូវទំនុកចិត្ត និងបណ្តាញដែលមានប្រសិទ្ធភាព ជាតម្រូវការនៅក្នុង មណ្ឌលរបស់គាត់ ដែលមានការលើកតម្កើងឆាប់រហ័តាមរយៈប្រព័ន្ធគណបក្ស ។ វាជាការ សំខាន់ដែលគណបក្ស នយោបាយ មានភាពសកម្មជាមុនក្នុងការអនុវត្តគោលនយោបាយ យេនឌ័រនាពេលអនាគតដើម្បីអោយស្ត្រីមាន តួនាទី កាន់តែរឹងមាំ។ ទោះបីជាយ៉ាងណាក៏ដោយ គណបក្ស នយោបាយទាំងនោះអាចមានទស្សនៈថាពួកគាត់មាន ការលំបាកក្នុងការស្វែងរកបេក្ខភាពជាស្ត្រីដែលមានសមត្ថភាព ដើម្បីឈរឈ្មោះ នៅលេខរៀងដំបូងនៃបញ្ជីឈរ ឈ្មោះ ។ ស្ត្រីដែលមានចំនេះដឹងខ្ពស់ មានសមត្ថភាព និងមានវ័យក្មេង អាចនឹងមិនចង់ធ្វើការនូវថ្នាក់មូលដ្ឋាន នោះទេ ។

## ២- កត្តាសង្គម និងកង្វះខាតការគាំទ្រ

ឥទ្ធិពលប្រពៃណី និងផ្នត់គំនិតរបស់ស្ត្រី រួមផ្សំនឹងនិន្នាការនយោបាយនៅកម្ពុជាផងនោះជះឥទ្ធិពលដល់ការ ចូលរួមរបស់ស្ត្រីនៅក្នុងជីវិតនយោបាយ ។ នៅប្រទេសកម្ពុជា អំណាច និងនយោបាយបានផ្សារភ្ជាប់យ៉ាងរឹង មាំទៅនឹងចរិតលក្ខណៈរបស់បុរសហើយតាមរយៈការយល់ឃើញនេះ វាអាចក្លាយជាការពិចារណាទៅលើការ កំណត់បុគ្គលិកលក្ខណៈរបស់ស្ត្រីផងដែរ ។ ស្ត្រីត្រូវបាន សង្កេតឃើញថារួមចំណែកខាន់ នឹងកិច្ចការផ្ទះ ។ ស្ត្រីជាច្រើននៅតាមខេត្តគឺ ប្រកាន់ភ្ជាប់ទៅនឹងគោលការណ៏វប្បធម៌ ប្រពៃណី ទំនៀមទម្លាប់កំណត់ដោយ ច្បាប់ស្រី ដែលទូន្មានអំពីតួនាទីរបស់ស្ត្រីដែលត្រូវប្រតិបត្តិស្វាមី និងកិច្ចការ ផ្ទះសំបែង ។ នេះមានន័យថាស្ត្រី ដែលអាចប្រឡូកក្នុងនយោបាយ នឹងត្រូវទទួលបន្ទុកទ្វេរដង គឺពួកគាត់មិនត្រឹម តែត្រូវទទួលខុសត្រូវលើ ការងារការិយាល័យមួយមុខនោះទេ តែថែមទាំងត្រូវរ៉ាប់រងនូវកិច្ចការផ្ទះផងដែរ ។ ការយល់ ច្រលំអាចនឹងនៅ តែបន្តមានដែលថាស្ត្រីមិនអាចធ្វើការដូចបុរស ខ្សោយជាងបុរស មិនអាច ដោះស្រាយនឹងបញ្ហា សន្តិសុខ នៅក្នុងសហគមន៍ពួកគាត់ ហើយនៅតែមិនអាចទទួលរ៉ាប់រងការងារផ្សេងទៀតដូចបុរសបានទេ[30] ។ ការយល់ ខុសទាំងនេះត្រូវ តែផ្លាស់ប្តូរប្រសិនបើស្ត្រីនឹងត្រូវដើរតួនាទីដ៏ពេញលេញនៅក្នុងជីវិតនយោបាយនៅថ្នាក់ មូលដ្ឋាននោះ ។

[29] Kim and Ojendal (2012)
[30] Ibid.

ជារឿយៗ តែងតែមានកង្វះខាតនូវការគាំទ្រចំពោះស្ត្រីក្នុងការចូលរួមក្នុងឆាកនយោបាយ ។ នេះគឺបំពាក់បំប៉នផង ដែរដល់ស្ត្រីអោយក្លាយជាអ្នកដែលស្វាហាប់សម្រាប់ស្ត្រីដែល ខ្វះនូវជំនឿជឿជាក់ និងសមត្ថភាពដើម្បីបំពេញការងារក្នុងតួនាទីសំខាន់ៗដូចជាថ្នាក់ដឹកនាំ មូលដ្ឋាន ដែលជួយពង្រឹងឡើងវិញនូវដំណោះស្រាយលើបញ្ហាដែលកើតមានពីដំបូង ទាក់ទិននឹងការកង្វះការគាំទ្រនោះ ។ ជាការសំខាន់ដែលស្វាមី និងសាច់ញាតិជាបុរសចូល រួមយ៉ាងសកម្មផងដែរនៅក្នុងដំណើរការលើកស្ទួយទំនាក់ទំនងយេនឌ័រ ។ ថ្នាក់ដឹកនាំជាស្ត្រីអាចនឹងមិនត្រូវបាន កោតសសើរពីមិត្តរួមការងារ ឬក្រុមប្រឹក្សាឃុំជាបុរស ឬក្នុងគណបក្សរបស់គាត់ ។ ថ្នាក់ដឹកនាំជាស្ត្រីមិនត្រឹមតែមិន មានការគាំទ្រគ្រប់គ្រាន់ពីបុរសនោះទេ ប៉ុន្តែពេលខ្លះពីសំណាក់ស្ត្រីគ្នាឯងផងដែរ[31] ។ បើយោងតាមកិច្ចសម្ភាសន៍ ជាមួយនឹងគណកម្មាធិការជាតិ សម្រាប់ការអភិវឌ្ឍប្រជាធិបតេយ្យថ្នាក់ក្រោមជាតិ ប្រធានបទយេនឌ័រមិនប្រាកដ ថាត្រូវបាន ស្វាគមន៍នៅក្នុងកិច្ចពិភាក្សាជាមួយបុរសនោះទេ ជាធម្មតាមន្ត្រីរាជការជាបុរស មានទស្សនៈអវិជ្ជមាន ក្នុងការលើកយកប្រធានបទទាក់ទងនឹងការលើកតម្កើងស្ត្រីជារបៀបវារៈនៃកិច្ចពិភាក្សា[32]។ ទោះជាយ៉ាងណាក៏ ដោយពេលខ្លះចរន្តនេះគឺកំពុងតែមានការផ្លាស់ប្តូរ ។ ស្ត្រីក្មេងៗជាច្រើននៅ ប្រទេសកម្ពុជាធ្វើដំណើរឆ្ងាយៗដើម្បី សិក្សា និងប្រកបធ្វើការនេះ ធ្វើអោយពួកគាត់មានឯករាជ្យភាព និងអាចកសាង ទំនុកចិត្តក្រៅពីបម្រាមគ្រួសារ ។

## ៣- ការអប់រំ

ដើម្បីបំពេញតួនាទីប្រកបដោយប្រសិទ្ធភាព ស្ត្រីក៏ត្រូវការផងដែរនូវកម្រិតចំនេះដឹងដ៏សមស្របមួយ គួបផ្សំទៅនឹងបទពិសោធន៍ផងដែរ ។ អក្ខរកម្ម និងចំនេះដឹងទាក់ទងនឹងការអនុវត្តកិច្ចការរដ្ឋបាល គឺជាកត្តាសំខាន់ក្នុងការជម្រុញសមភាពយេនឌ័រ និងធ្វើអោយសមាជិកក្រុមប្រឹក្សាឃុំជាស្ត្រីជ្រាបអោយបានកាន់តែច្បាស់ពីបញ្ហាទាំងឡាយ ដូចជាការគ្រប់គ្រងហិរញ្ញវត្ថុ ការរៀបចំផែនការ និងថវិកា ដែលជាគន្លឹះក្នុងការផ្តល់នូវសេវាថ្នាក់មូលដ្ឋានប្រកបដោយប្រសិទ្ធភាព ។ កង្វះខាតការយល់ដឹង គឺជាកត្តាមួយក្នុងចំណោមកត្តាសំខាន់ៗជាច្រើនដែលពន្យល់ បញ្ជាក់ពីអតុល្យភាពនៃទំនាក់ទំនងយេនឌ័រនៅក្នុងប្រទេសកម្ពុជា ។ កត្តានេះមិនត្រឹមតែជះឥទ្ធិពលដល់ការងារ ប្រចាំថ្ងៃរបស់ស្ត្រីប៉ុណ្ណោះទេ តែថែមទាំងប៉ះពាល់ដល់ទំនុកចិត្តក្នុងការបំពេញការងាររបស់ពួកគាត់ផងដែរ ។ ទោះបីជាមានភ័ស្តុតាងបង្ហាញពីការកើនឡើងនូវការបញ្ជូនក្មេងស្រីអោយចូលរៀនក៏ដោយ ក៏អត្រានៃការបោះបង់ ការសិក្សារបស់ពួកគេកម្រិតក្នុងអនុវិទ្យាល័យត្រូវបានចាត់ទុកថាជាបញ្ហាប្រឈមដ៏ធំមួយ ជាពិសេសនៅតាមតំបន់ជនបទ និងតំបន់ដាច់ស្រយាល ។ បើយោងតាមវិទ្យាស្ថានស្ថិតិជាតិ[33] ការបោះបង់ការសិក្សារបស់ក្មេងស្រី នៅអាយុ ៧-១១ គឺខ្ពស់ជាងក្មេងប្រុស ។

---

31 Prak and Schuette (2007), Gender and Women Politics in Cambodia, Heinrich Boll Stifung, Cambodia.
32 Information obtained through interview with Ms. Henny Anderson and Ms. Mary Sok, 14th December 2012
33 National Institute of Statistics, Education Statistics Database, 2009-2010, MoEYS, Cambodia

## ៤- ភាពឯករាជ្យខាងសេដ្ឋកិច្ច

កង្វះខាតភាពឯករាជ្យខាងសេដ្ឋកិច្ច គឺជាឧបសគ្គដ៏ចំបងផងដែរក្នុងការអភិវឌ្ឍសមភាព និងទំនាក់ទំនងស្មើភាពគ្នារវាងបុរសនិងស្ត្រី ។ ស្ត្រីនៅតាមខេត្ត ជារឿយៗត្រូវបានបដិសេធនូវលទ្ធភាពក្នុងការទទួលបាននូវធនធានដែល ពួកគេត្រូវការដើម្បីបំពេញតួនាទីអោយបានពេញលេញនៅក្នុងឆាកនយោបាយ ជាពិសេសនៅតាមទីជនបទ ដែលទស្សនៈចំពោះការចូលរួមរបស់ស្ត្រីនៅក្នុងនយោបាយមិនត្រូវបានស្វាគមន៍ ឬទទួលស្គាល់ពេញលេញនោះទេ ។ ឯករាជ្យភាពខាងសេដ្ឋកិច្ចត្រូវតែចាប់ផ្តើមពីកិច្ចការផ្ទះ និងនៅក្នុងរង្វង់គណបក្សនយោបាយ ប្រសិនស្ត្រីមាន បំណងបំពេញតួនាទីប្រសើរជាងនេះ ។ កង្វះខាតធនធានហិរញ្ញវត្ថុ មានន័យថា នៅពេលដែលស្ត្រីបង្ហាញពី អាទិភាពរបស់ខ្លួន គឺមិនមានប្រសិទ្ធិភាពនោះទេ បើគ្មានការគាំទ្រជាជុំកំភួនពីអង្គការក្រៅរដ្ឋាភិបាល និងមូលនិធិ ឃុំ-សង្កាត់ ឬពីអាជ្ញាធរថ្នាក់ជាតិ ឬគ្មានប្រសិទ្ធភាពព្រោះគ្មានការគាំទ្រផ្នែកសម្ភារៈពីអង្គការក្រៅរដ្ឋាភិបាលថវិកា ឃុំ-សង្កាត់ ឬពីរដ្ឋាភិបាលថ្នាក់កណ្តាល[34] ។

## ៥- ការអនុវត្តគោលនយោបាយ

ទោះបីច្បាប់ និងគោលនយោបាយជាច្រើនដែលលើកកម្ពស់សមភាពយេនឌ័រ ហើយជាក់ស្តែងទោះបីជាកម្ពុជា មានក្របខ័ណ្ឌដែលបានចងក្រងជាឯកសារបានត្រឹមត្រូវ និងទូលំទូលាយនៃបទបញ្ញត្តិជាតិ និងអនុសញ្ញាអន្តរជាតិនានាសំដៅដល់ការលើកកម្ពស់សិទ្ធិ និងតួនាទីស្ត្រីយ៉ាងណាក៏ដោយ ក៏ការអនុវត្តនិងការពង្រឹងការអនុវត្តច្បាប់នៅមានលក្ខណៈយឺតយ៉ាវនៅឡើយ ។ ជាទូទៅ គោលនយោបាយ និងបទបញ្ញត្តិទាក់ទងនឹងបញ្ហាយេនឌ័រ មិនត្រូវ បានគេស្វែងយល់ច្បាស់លាស់នៅឡើយទេ ហើយការជម្រុញ និងលើកកម្ពស់បញ្ហាយេនឌ័រជាសាធារណៈ ក៏មិនបានធ្វើឡើងដោយអនុលោមតាមបទបញ្ញតិ និងគោលនយោបាយដែលមាននោះដែរ ។ ការកំនត់តួនាទីអោយបានជាក់លាក់ និងការតភ្ជាប់បណ្តាញ ទំនាក់ទំនងអោយបានប្រសើរជាងមុនរវាងថ្នាក់ឃុំ គណបក្សនយោបាយ និងបុគ្គល អាចជួយដល់ការសម្រួលដល់ការអនុវត្តគោលនយោបាយ"[35] ។

ជាជាងការអនុវត្តតាមមាគ៌ាណែនាំថ្នាក់ជាតិ ការអនុវត្តន៍អាចនឹងប្រតិបត្តិតាមគោលនយោបាយ របស់គណបក្សនយោបាយ ។ ការអនុវត្តពេញលេញអាចជាបញ្ហានៃការខ្វះខាតធនធាននៅថ្នាក់មូលដ្ឋានក្នុងការដោះ ស្រាយនូវបញ្ហាអោយបានគ្រប់ជ្រុងជ្រោយនៅក្នុងសហគមន៍ ដូចជាអំពើហឹង្សាក្នុងគ្រួសារ និងភាពក្រីក្រ ។ សរុបមក មានវត្តមាននៃគោលនយោបាយ ប៉ុន្តែត្រូវបានរារាំងដោយបញ្ហានៃការអនុវត្ត ដោយសារតែផលប៉ះពាល់ ដែលតែងតែកើតមាននៃបទដ្ឋានសង្គម កង្វះខាតការគាំទ្រផ្នែកហិរញ្ញវត្ថុ និងឆន្ទៈនយោបាយដើម្បីជម្រុញអោយ បានពេញទំហឹងតាមរយៈគោលនយោបាយទាំងឡាយនេះ[36] ។

---

[34] Kim and Ojendal (2012)

[35] Ibid.

[36] Ibid.

### ៦- ការបញ្ចេញទស្សនៈក្នុងការចេញសេចក្តីសម្រេចចិត្តថ្នាក់មូលដ្ឋាន

វត្តមានស្ត្រីនៅក្នុងតំណែងតែមួយមុខគត់គឺមិនគ្រប់គ្រាន់នោះទេ សម្លេងរបស់គាត់ ត្រូវតែមានការទទួលដឹងលឺ ហើយស្ត្រីត្រូវតែអាចបំពេញការងារ និងផលប្រយោជន៍របស់ពួកគាត់ត្រូវបានស្វែងយល់ និងយកចិត្តទុកដាក់ក្នុង កិច្ចពិភាក្សាដេញដោលនយោបាយ ។ តាមរយៈនេះ ឆន្ទៈដ៏មោះមុតក្នុងការបំពេញការងារលើបញ្ហាសំខាន់ៗរបស់ សហគមន៍អាចបង្កើនប្រជាប្រិយភាពក្រុមប្រឹក្សាឃុំជាស្ត្រី ដែលអាចអោយពួកគាត់កាន់តែទទួលបាននូវការពេញ ចិត្តពីសំណាក់គណបក្សរបស់ខ្លួនបន្ថែមទៀត ។ ដំណោះស្រាយប្រកបដោយប្រសិទ្ធភាពចំពោះបញ្ហានៅមូលដ្ឋាន ផ្តល់ដល់ស្ត្រីនូវភាពត្រឹមត្រូវតាមផ្លូវច្បាប់នៅក្នុងសហគមន៍ ប៉ុន្តែស្ត្រីអាចប្រឈមនឹងហានិភ័យប្រសិនជាពួកគាត់ ធ្វើការនៅតំបន់ដែលមានឥទ្ធិពលប្រពៃណីខ្លាំង បញ្ហាទាំងនោះមានដូចជាអំពើហឹង្សាក្នុងគ្រួសារ ការថែទាំកូនចៅ សុខុមាលភាពសង្គម និងការងារផ្ទះសំបែង ។ ការកែប្រែនូវទម្លាប់ទាំងអស់នេះនឹងក្លាយទៅជាគន្លឹះដើម្បីធ្វើអោយ មានភាពស្របច្បាប់ជារួមលើការបញ្ចេញសម្លេងរបស់ស្ត្រីនៅថ្នាក់មូលដ្ឋាន ។ ជារួម ការទទួលបានប្រជាប្រិយភាព ពីសំណាក់ប្រជាជន ការបំពេញការងារប្រកបដោយតម្លាភាព និងមានការប្តេជ្ញាចិត្ត ចំពោះសហគមន៍គឺជាកត្តាគន្លឹះ ដែលលើកស្ទួយសម្លេងនយោបាយរបស់ស្ត្រីនៅថ្នាក់មូលដ្ឋាន ។ ដូច្នេះ សមត្ថភាពពិតប្រាកដរបស់ស្ត្រីដែលបាន បញ្ចេញ និងបង្ហាញក្នុងពេលបំពេញភារកិច្ចរបស់គាត់ប្រកបដោយ ប្រសិទ្ធភាពនោះ គឺអាចទទួលបានតាមរយៈ ទំនុកចិត្តនិងកិច្ចសហការដែលពួកគាត់ទទួលបានពីការជ្រោមជ្រែង ពីបុរសដែលជួយអោយការបញ្ចេញមតិរបស់ ពួកគាត់កាន់តែមានប្រសិទ្ធិភាព និងទទួលបានឥទ្ធិពលនៅក្នុងវេទិកានានា[37] ។ វត្តមានរបស់ស្ត្រីនៅក្នុងតួនាទី ដឹកនាំគឺជារឿងកម្រមួយ ។ ជារឿយៗ គេសង្កេតឃើញថា នៅពេលដែលស្ត្រីត្រូវបានជ្រើសរើសអោយចូលរួម កិច្ចការនយោបាយមូលដ្ឋាន ពួកគាត់អាចទទួលបានតំណែងនៅថ្នាក់ទាបប៉ុណ្ណោះ ។ ជាក់ស្តែង នៅពេលដែលពួក គាត់បំពេញការងារនៅក្នុងក្រុមប្រឹក្សាឃុំ ពួកគាត់តែងតែដើរតួនាទីជាអ្នកគាំទ្រ ជាជាងដើរតួនាទីពេញលេញជាអ្នកធ្វើការសម្រេចចិត្ត[38] ។

ជារួម កត្តាគន្លឹះផ្សេងៗ ដែលអាចអោយស្ត្រីបញ្ចេញមតិរបស់ពួកគាត់យ៉ាងពេញលេញនៅថ្នាក់មូលដ្ឋាន គឺ

- ការទទួលបាននូវធនធានហិរញ្ញវត្ថុ និងសិទ្ធិធ្វើការសម្រេចចិត្តតាមផ្លូវច្បាប់
- ការទទួលបានការគាំទ្រ និងទំនុកចិត្តពីគណបក្សរបស់ពួកគាត់គឺជាជំនួយនៅពេលដែលពួកគាត់មានទំនាក់ទំនងរយៈពេលយូរជាមួយគណបក្ស ។

---

[37] Ibid.

[38] Information obtained through interview with NCDD advisor Ms. Henny Anderson and Ms. Mary Sok, 14th December 2012

-កំរិតនៃការអប់រំ និងបទពិសោធន៍គ្រប់គ្រាន់ ព្រមទាំងការបង្កើនសមត្ថភាពក្នុងភាពជាអ្នកដឹកនាំ និងការគ្រប់គ្រងហិរញ្ញវត្ថុ ។ល។

- មានការជឿជាក់លើខ្លួនឯង
- ប្រជាប្រិយភាព មានការគាំទ្រ និងទទួលបានទំនុកចិត្តពីសហគមន៍[39] ។

## VIII- តួនាទីសមាជិកសភាក្នុងការពង្រឹងតួនាទីស្ត្រីក្នុងការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ

សភាអាចដើរតួនាទីយ៉ាងសំខាន់ក្នុងការលើកកម្ពស់តួនាទីស្ត្រីក្នុងឆាកនយោបាយ តាមរយៈមុខងារនីតិកម្ម តំណាង និងត្រួតពិនិត្យ ។ សមាជិកព្រឹទ្ធសភាប្រមាណជា៩៣% ត្រូវបានបោះឆ្នោតជ្រើសរើសដោយក្រុមប្រឹក្សា ឃុំសង្កាត់ ហើយមុខងារតំណាងរបស់សមាជិកសភា ផ្តល់សមាជិកព្រឹទ្ធសភានូវតួនាទីយ៉ាងសំខាន់ក្នុងការកសាងសមត្ថភាពដល់ក្រុមប្រឹក្សាឃុំសង្កាត់ ។ ទោះបីជាយ៉ាងណាក៏ដោយជាការសំខាន់ដែលសភាគួរយកចិត្តទុកដាក់ស្តាប់ និងធ្វើការអោយបានជិតស្និទ្ធជាមួយប្រជាជនក្នុងសហគមន៍ គឺមិនត្រឹមតែជាមួយស្ត្រីនោះទេ ដើម្បីយល់ដឹងឧបសគ្គដែលរារាំងស្ត្រីក្នុងការដើរតួនាទីពេញលេញក្នុងឆាកនយោបាយ[40] ។ ស្ត្រីត្រូវការការគាំទ្រពីសំណាក់ក្រុមគ្រួសារ និងសហគមន៍ ក្នុងការចូលរួមចំណែកក្នុងវិស័យការងារ ហើយសភាមានតួនាទីស្តាប់នូវបញ្ហារបស់ប្រជាជនក្នុងសហគមន៍ និងចូលរួមវេទិកាសាធារណៈ ដើម្បីដោះស្រាយបញ្ហាទាំងឡាយទាក់ទងនឹងបញ្ហាយេនឌ័រ ។ សមាជិកសភាអាចប្រើប្រាស់តួនាទីរបស់ខ្លួនដោយទំនាក់ទំនងជាមួយស្ត្រីនៅក្នុងមណ្ឌលរបស់ខ្លួន និងតាមរយៈវេទិកាសាធារណៈ ដោយលើកទឹកចិត្តស្ត្រីឲ្យចូលរួមកិច្ចប្រជុំ និងការបញ្ចេញមតិ ផ្តល់វគ្គបណ្តុះបណ្តាល និងព័ត៌មាន និងជម្រុញស្ត្រីឲ្យក្លាយជាអ្នកដឹកនាំ ។ ជំហានដែលបានរៀបរាប់ខាងលើត្រូវការពេលវេលាដើម្បីសម្រេចបានដើម្បីឈានទៅរកការចូលរួមដ៏ពិតប្រាកដ ។

ការអនុវត្តច្បាប់ និងគោលនយោបាយនៅតែជាបញ្ហា ហើយសភាគួរតែត្រួតពិនិត្យ និងកែប្រែច្បាប់មួយចំនួនដើម្បីអោយស្ត្រីទទួលបាននូវការយកចិត្តទុកដាក់ និងសិទ្ធិដ៏ពិតប្រាកដ ។ ឧទាហរណ៍ ច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ-សង្កាត់ អាចរួមបញ្ចូលនូវសមាសភាពយេនឌ័រ និងគួរតែមានការយល់

[39] Kim and Ojendal (2012)

[40] Information obtained through interview with NCDD advisor Ms. Henny Anderson and Ms. Mary Sok, 14th December 2012

ដឹងពីរបៀបធ្វើការងារជា មួយក្រុមបច្ចេកទេសក្នុងក្រសួងដើម្បីអនុវត្តច្បាប់ដែលបានបញ្ចូលសមាសភាពយេនឌ័ររួចហើយ[41]។

បន្ថែមពីលើនេះ សភាគួរសិក្សាលម្អិតទៅលើការបែងចែកថវិកាសម្រាប់កម្មវិធីដែលទាក់ទងនឹងស្ត្រី និងថាតើការផ្តល់ថវិកាមានភាពគ្រប់គ្រាន់ក្នុងការឆ្លើយតបទៅនឹងតម្រូវការរបស់ស្ត្រីនៅក្នុងថ្នាក់មូលដ្ឋានដែរឬទេ។ សមាជិកសភាគួរតែប្រើអំណាចរបស់ខ្លួនក្នុងការបញ្ចុះបញ្ចូលអភិបាលខេត្ត ក្នុងការអនុវត្តការលើកកម្ពស់ការយល់ដឹងការ កសាងសមត្ថភាព និងការតស៊ូមតិ ដើម្បីអោយប្រាកដថាមន្រ្តីថ្នាក់ខេត្តមាន ការយល់ដឹងពេញលេញមានការយល់ដឹងពីសកម្មភាព និងកម្មវិធីដែលទាក់ទងនឹងយេនឌ័រ[42]។ គណៈកម្មការជំនាញរបស់សភាគួរពង្រឹង ទំនាក់ទំនងជាមួយបណ្តាក្រសួងនានាក្នុងជួររដ្ឋាភិបាល និងអង្គការក្រៅរដ្ឋាភិបាលមួយចំនួនដែលមានកម្មវិធីស្រដៀងគ្នាដើម្បីទទួលនូវព័ត៌មានថ្មីៗ នូវបញ្ហាដែលទាក់ទងនឹងការបញ្រ្ជាបយេនឌ័រនៅក្នុងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ។

## IX- សេចក្តីសន្និដ្ឋាន

នៅប្រទេសកម្ពុជា ស្ថានភាពស្ត្រីមានភាពល្អប្រសើរជាងមុន ប៉ុន្តែការផ្តល់សិទ្ធិដល់ស្ត្រីអោយបានពេញលេញក្នុងឆាកនយោបាយនៅតែមានឧបសគ្គនៅឡើយ ។ ការលើកកម្ពស់ឋានៈរបស់ស្ត្រីក្នុងសង្គមប្រៀបបីដូចជាការផ្គុំរូបភាពតូចៗ ដែលចាំបាច់ត្រូវការចំណែកនៃរូបភាពទាំងនោះអោយសមស្របជាមួយគ្នា ដើម្បីបានរូបភាពពេញលេញមួយ ។ រូបភាពដំបូងគឺការអប់រំស្ត្រីអោយទទួលបាននូវចំណេះដឹងគ្រប់គ្រាន់អំពីតួនាទី និងសក្តានុពល របស់ខ្លួន ។ ចំណែករូបភាពទីពីរនៃការផ្គុំរូបភាពគឺ ការបង្កើតអំណាចចន្ទ្រះនយោបាយដល់ស្ត្រី និងត្រួតពិនិត្យការអនុវត្តច្បាប់ទាក់ទងនឹងយេនឌ័រ ។ ការគាំទ្រពីបុរសក៏ជាផ្នែកមួយសំខាន់ដែរ ដែលពួកគាត់ត្រូវផ្លាស់ផ្តូរការវិនិច្ឆ័យ របស់ខ្លួនចំពោះមិត្តរួមការងារជាស្ត្រីទាំងនៅផ្ទះ និងកន្លែងការងារ ដើម្បីជួយលើកកម្ពស់ស្ត្រីឲ្យទទួលបាននូវតួនាទី សំខាន់ ក្នុងវិស័យនយោបាយអោយបានប្រសើរជាងមុន ។ ស្ត្រីក៏ត្រូវមានភាពជឿជាក់លើខ្លួនឯងដើម្បីបង្កើនសំលេងរបស់ខ្លួននៅក្នុងសង្គម ។ ភាពជោគជ័យរបស់ស្ត្រីក្នុងឆាកនយោបាយពឹងផ្អែកលើកត្តាមួយចំនួនដូចជា អាទិភាពនៅក្នុងគណបក្សនយោបាយ អត្តចរិកបុគ្គល ប្រវត្តិនៅក្នុងសហគមន៍ និងឥរិយាបថរបស់បុគ្គល[43] ។ សរុបសេចក្តីមក ស្ត្រីដែលទទួលបានភាពជោគជ័យក្នុងឆាកនយោបាយគឺនៅពេលដែលពួកគាត់ទទួលបានការគាំទ្រជាសាធារណៈក្នុងសហគមន៍ ដែលជាកត្តា

---

[41] Information obtained through interview with Mr. The Chunkhank , Deputy General Director of Ministry of Women's Affairs, 12th December 2012

[42] Information obtained through interview with Ms. Henny Anderson and Ms. Mary Sok, 14th December 2012

[43] Kim and Ojendal (2012)

ជម្រុញតួនាទីរបស់ពួកគាត់នៅក្នុងគណបក្ស ។ កត្តានេះត្រូវតែទទួលបាននូវការគាំទ្រពីបទបញ្ញត្តិច្បាប់ និងគោលនយោបាយសាធារណៈ ដែលមានការអនុវត្តបានល្អប្រសើរ[44] ។

X- ចំនុចដែលគួរពិចារណាបញ្ហាសម្រាប់ពិចារណានាពេលខាងមុខ

- យុវវ័យគឺជាគោលដៅចម្បងក្នុងការបញ្ជ្រាបសមភាពយេនឌ័រ ហើយការបញ្ជ្រាបនេះគួរតែធ្វើឡើងពីថ្នាក់ ក្រោមទៅថ្នាក់លើ ។ ជំហានដំបូងក្នុងការផ្តល់សិទ្ធិអំណាចដល់ស្ត្រីឲ្យដើរតួនាទីពេញលេញនៅគ្រប់វិស័យនៃសង្គម គឺការបង្កើនលទ្ធភាពក្នុងការទទួលបានការអប់រំ និងបង្កើនការអប់រំដល់សិស្សជានារីពីដល់អនុវិទ្យាល័យនិងថ្នាក់បន្ទាប់ទៀត ។ ក្រសួងកិច្ចការនារី បានខិតខំ អំពាវនាវឲ្យមានការ យកចិត្តទុកដាក់បន្ថែមទៀតក្នុងការរៀបចំកម្មវិធី សិក្សាសម្រាប់ស្ត្រី និងបញ្ជ្រាបការលើកស្ទួយសិទ្ធិ និងសម្លេងរបស់ស្ត្រីក្នុងកម្មវិធីសិក្សាជាតិ ។

- ការអប់រំក៏ជាគន្លឹះសម្រាប់បុរសក្នុងការយល់ដឹងអំពីសេចក្តីត្រូវការរបស់ស្ត្រី និងបញ្ហាយេនឌ័រ ។ ការគាំទ្រពីបុរសគឺជាការចាំបាច់ ព្រោះបច្ចុប្បន្ននេះ បុរសក្នុងសង្គម និងជាអ្នកកាន់អំណាច ការយល់ដឹងមិនបានពេញលេញអំពីទស្សនៈយេនឌ័រ និងវិធីសាស្ត្រដែលអាចលើកកម្ពស់តួនាទីរបស់ស្ត្រីនៅក្នុងឆាកនយោ បាយ ដែលនេះអាចជាទិសដៅនៃការតស៊ូមតិ ។

- ជំហានបន្ទាប់គឺ ស្ត្រីត្រូវបង្កើនការចូលរួមក្នុងវគ្គបណ្តុះបណ្តាលពីបញ្ហាដែលអាចឲ្យស្ត្រីដើរតួនាទីដ៏រឹងមាំក្នុងឆាកនយោបាយ ដែលរួមមាននីតិវិធីរដ្ឋបាល អភិបាលកិច្ចមូលដ្ឋាន និងចំណេះដឹងពីសិទ្ធិ និងគោលនយោបាយសំខាន់ៗ ។ បច្ចុប្បន្ន ក្រុមប្រឹក្សាជាស្ត្រីបានបង្ហាញថា ពួកគាត់មិនមានការយល់ដឹងច្បាស់លាស់ពីប្រព័ន្ធនយោបាយ ដែលនេះជាការរារាំងគាត់មិនឲ្យបញ្ចេញយោបល់ ឫផ្តល់គំនិតទៅលើការងារ ដែលពួកគាត់កំពុងតែបំពេញ ។

- ការអប់រំ និងសមត្ថភាពគឺជាកត្តាសំខាន់ ប៉ុន្តែដើម្បីឲ្យស្ត្រីមានភាពជោគជ័យក្នុងការដើរតួនាទីនយោបាយនៅថ្នាក់មូលដ្ឋាន ស្ត្រីត្រូវការការគោរព អត់ធ្មត់ និងចិត្តសប្បុរស គ្មានការរើសអើង និងលេចធ្លោក្នុងនយោបាយរបស់គណបក្ស[45] ។ ក្នុងការតស៊ូមតិទៅលើបញ្ហាមួយចំនួនដូចជាសុខភាព ការអប់រំ និងដំណោះស្រាយជំលោះ ស្ត្រីត្រូវបានសង្កេតឃើញថាទទួលបានជោគជ័យ និងមានប្រសិទ្ធភាពជាងបុរស ។ ជាការសំខាន់ដែលស្ត្រីមានភាពវ័យឆ្លាត មានការអប់រំខ្ពស់ និងមាន

---

[44] Ibid.

[45] Kim and Ojendal (2012)

ប្រជាប្រិយភាពនៅក្នុងសហគមន៍ ដើម្បីឲ្យពួកគាត់អាចដោះស្រាយជាស្ថានភាពមូលដ្ឋានបានល្អប្រសើរ ហើយនៅមូលដ្ឋានដែលមានបេក្ខភាពនារីដែលបំពេញនូវកត្តានេះពួកគាត់គួរតែត្រូវបានផ្តល់អាទិភាពដោយគណបក្សនយោបាយលើបញ្ជីឈ្មោះ ។

- ភាពជាតំណាងរបស់ស្ត្រីក្នុងនយោបាយថ្នាក់មូលដ្ឋានពឹងផ្អែកយ៉ាងខ្លាំងលើអាទិភាពរបស់គណបក្សនយោបាយ ។ កូតានៅក្នុងស្ថាប័ននយោបាយ និងរដ្ឋបាល អាចជាជំហានដ៏សមស្របក្នុងការបង្កើនភាពជាតំណាងរបស់ស្ត្រី ប៉ុន្តែកត្តានេះគួរតែដើរទន្ទឹមគ្នាជាមួយការពង្រឹងសមត្ថភាព និងសំលេងរបស់ស្ត្រី ផងដែរ ។

- ឯករាជ្យភាពខាងសេដ្ឋកិច្ចរបស់ស្ត្រីគឺជាកត្តាសំខាន់ក្នុងការបង្កើនការចូលរួមរបស់ស្ត្រីក្នុងឆាក នយោបាយ ។ ស្ថេរភាពហិរញ្ញវត្ថុអាចឲ្យស្ត្រីជ្រើសរើសនូវអ្វីដែលគាត់ចង់ធ្វើ ។ ជាងនេះទៅទៀតសមាជិកាក្រុម ប្រឹក្សាឃុំ-សង្កាត់ត្រូវការមូលនិធិសម្រាប់គម្រោង និងសេវាដែលពួកគាត់ស្នើឡើងក្នុងការពិគ្រោះយោបល់ ជាមួយសហគមន៍មូលដ្ឋានក្នុងការបង្កើនឥទ្ធិពលនយោបាយរបស់ខ្លួន ។

- ការគាំទ្រពីបុរស និងក្រុមគ្រួសារគឺជាកត្តាសំខាន់ ដែលនេះរួមបញ្ចូលក្នុងការព្យាយាមលើកទឹកចិត្តស្ត្រីអោយចូលរួមកិច្ចប្រជុំក្រុមប្រឹក្សាឃុំ-សង្កាត់ ព្រមទាំងលើកឡើងនូវទស្សនៈ និងមតិយោបល់របស់ពួកគាត់ ។

- សភាអាចដើរតួនាទីយ៉ាងសំខាន់ក្នុងការពង្រឹងផ្តល់ព័ត៌មានដែលមានសារៈសំខាន់សម្រាប់ស្ត្រីនៅជនបទ ដើម្បីឲ្យពួកគាត់មានការយល់ដឹងជាមុនអំពីសិទ្ធិ ច្បាប់ និងគោលនយោបាយដែលមានក្នុងការគាំទ្រឆាកជីវិត និងការចូលរួមរបស់ពួកគាត់ក្នុងសង្គម និងឆាកនយោបាយ ។

- ដៃគូអភិវឌ្ឍន៍គួរតែបន្តផ្តល់ការគាំទ្រផ្នែកបច្ចេកទេសដល់រាជរដ្ឋាភិបាលក្នុងការអភិវឌ្ឍយន្តការដែលមាន ប្រសិទ្ធិភាពក្នុងការបញ្ជ្រាបយេនឌ័រនៅថ្នាក់ក្រោមជាតិ ។

- យន្តការដោះបណ្តឹងគួរតែមានវត្តមានជាបន្តក្នុងការបង្កើនតម្លាភាព និងគណនេយ្យភាព ដូចនេះបញ្ហារបស់ស្ត្រីអាចត្រូវបានដោះស្រាយ និងដឹងលឺបានទូលំទូលាយ និងអាចត្រូវបានដោះស្រាយប្រកបដោយប្រសិទ្ធិភាព ។

# បញ្ជីឯកសារយោង


Asima Yanty. S, 2004, "Women and local governance in Indonesia: A case study of engendering local governance in North Sumatra".

CCHR, 2012, "Briefing Note on Female Political Representation and Electoral Gender Quota systems"

CNCW,  Background of the Cambodian National Council for Women (CNCW), from http://cncw.gov.kh/

Committee to Promote Women in Politics (CPWP), from: http://www.cpwp.net/

Jean Munro, 2012, "Women's representation in leadership in Vietnam", UNDP.

Jean-Marc Lepain, 2011,  "Decentralization and Deconcentralization Cambodia: Progress and Issues"

Kim & Ójendal, 2012, "A Gendered Analysis Of Decentralization Reform in Cambodia", CDRI, Phnom Penh, Cambodia.

Lara Griffiths, 2010, "Strengthening Democracy and Electoral Process in Cambodia", UNDP Cambodia

Ministry of Planning, 2005 "Achieving the Cambodia Millennium Development Goals," Royal Government of Cambodia.

Ministry of Women's Affairs, April 2008. *Cambodia Gender Assessment: "A Fair Share For Women", chapter 7: "Gender disparities in politics and Public decision making"*

Ministry of Women's Affairs, July 2012*, "Women's Political Participation in Cambodia : Policy/mechanism, Progress and lesson learnt"*

Ministry of Women's Affairs, 2009, *Neary Rattanak III*, Five Year Strategic Plan 2009-2013.

National Election Committee (NEC) Updated, 2012

National Institute of Statistics, Education Statistics Database, 2009-2010, MoEYS, Cambodia

National Program for Sub-National Democratic Development (NP-SNDD) 2010-2019

National Program for Sub-National Democratic Development (NP-SNDD) 2010-2019, Annex 2: *Gender Mainstreaming for Sub-national Administrations*

Prak and Schuette, 2007, "Gender and Women Politics in Cambodia", Heinrich Boll Stifung, Cambodia.

Thailand women overview, http://asiapacific.unwomen.org/en/countries/thailand

UNDP, 2010, "Women in local government in Asia Pacific Status Report"
UN-HABITAT, 2008 "Gender mainstreaming in local authorities: Best practices
United Nation Economic and Social Council (ECOSOC), 1997 from website:
http://www1.aucegypt.edu/src/engendering/definitions.html#Gender%20Mainstreaming

# បទសម្ភាស

Interview result with Ms. Men Vannavy, CPWP Program Coordinator, dated 25th December, 2012, Phnom Penh, Cambodia

Interview with Henny Anderson and Mary Sok, NCDD consultants, dated 14th December, 2012, Phnom Penh, Cambodia.

Interview´s with Mr. The Chunkhank , Deputy General Director of Ministry of Women´s Afairs, dated 12th December, 2012. Phnom Penh, Cambodia.

ឧបសម្ព័ន្ធ: **ភាពជាតំណាងរបស់ស្ត្រីក្នុងឆាកនយោបាយ: បទពិសោធន៍ប្រទេសកម្ពុជា និងអន្តរជាតិ**

**តារាង ១: ការប្រៀបធៀបភាពជាតំណាងក្នុងវិស័យនយោបាយរបស់ស្ត្រីរវាងថ្នាក់ជាតិ និងក្រោមជាតិ ក្នុងខែតុលា ឆ្នាំ២០១០**

| ប្រទេស | តំណាងស្ត្រីថ្នាក់ជាតិ (%) | តំណាងស្ត្រីនៅថ្នាក់ក្រោមជាតិសរុប (%) |
|---|---|---|
| អាហ្គានីស្ថាន | ២៧.៣ | ៣០ |
| អូស្ត្រាលី | ២៧.៣ | ២៨.១០ |
| ឥណ្ឌា | ១០.៨ | ៣៧ |
| ណូវែលសេឡង់ | ៣៣.៦ | ២៩.៤០ |
| វៀតណាម | ២៥.៨ | ២២.១៤ |

*ប្រភព: របាយការណ៍រដ្ឋាភិបាលមូលដ្ឋាននៅអាស៊ីប៉ាស៊ីហ្វិក ២០១០ ,UNDP*

**តារាង ២: ទិន្នន័យតំណាងជាស្ត្រីដែលបានជាប់ឆ្នោតនៅក្រុមប្រឹក្សានៅជនបទក្នុងខែតុលា ឆ្នាំ២០១០**

| ប្រទេស | តំណាងស្ត្រីជាប់ឆ្នោត | | | ស្ត្រីជាប្រធាន | | |
|---|---|---|---|---|---|---|
| | ចំនួនតំណាងជាប់ឆ្នោតសរុប, រួមទាំងប្រធាន(#) | ចំនួនតំណាងជាប់ឆ្នោតជាស្ត្រី (#) | តំណាងស្ត្រីជាប់ឆ្នាត (%) | ចំនួនប្រធានក្រុមប្រឹក្សា (#) | ចំនួនស្ត្រីជាប្រធានក្រុមប្រឹក្សា(#) | ស្ត្រីជាប្រធានក្រុមប្រក្សា (%) |
| អាហ្គានីស្ថាន: ខេត្ត | ៤២០ | ១២៥ | ៣០ | ៣៤ | ៥ | ១៥ |
| ណូវែលសេឡង់: ភូមិភាគ, ក្រុង និងក្រុមប្រឹក្សាសង្កាត់ | ៩៩៩ | ២៩៤ | ២៩,៤ | ៨៥ | ១៤ | ១៦ |
| ហ្វីលីពីន | NA | NA | NA | ៨១ | ១៦ | ១៩,៨ |

*ប្រភព: របាយការណ៍រដ្ឋាភិបាលមូលដ្ឋាននៅអាស៊ីប៉ាស៊ីហ្វិក ២០១០ ,UNDP*

## តារាង ៣: ការបោះឆ្នោតឃុំសង្កាត់នៅប្រទេសកម្ពុជា

| អាណត្តិ និងឆ្នាំ | សមាជិកក្រុមប្រឹក្សា | | ប្រធានឃុំសង្កាត់/ | | អនុប្រធានទី១ | | អនុប្រធានទី២ | |
|---|---|---|---|---|---|---|---|---|
| | សរុប | ស្ត្រី | សរុប | ស្ត្រី | សរុប | ស្ត្រី | សរុប | ស្ត្រី |
| ២០០២ | ១១,២១៦ | ១,០៥៦ (៩.៤%) | ១៦២១ | ៤២ (២.៦%) | ១៦២១ | ៧២ (៤.៤%) | ១៦២១ | ៨៦(៥.៣%) |
| ២០០៧ | ១១,៣៥៣ | ១,៧១៧ (១៥.១%) | ១៦២១ | ៦៧ (៤.១%) | ១៦២១ | ១៥១ (៩.៣%) | ១៦២១ | ១៣១(៨%) |
| ២០១២ | ១១,៤៥៩ | ២០៣៨ (១៧.៧%) | ១៦៣៣ | ៩៦ (៥.៨%) | ១៦៣៣ | ១៨៩ (១១.៦%) | ១៦៣៣ | ១៥១ (៩.២%) |

*ប្រភព: គណៈកម្មការជាតិរៀបចំការបោះឆ្នោត NEC, ២០១២*

## តារាង ៤: ចំនួនជាភាគរយនៃស្ត្រីនៅថ្នាក់ខេត្ត ឃុំ និងសង្កាត់នៃក្រុមប្រឹក្សារវាងអាណត្តិ ១៩៩៩-២០០៤, ២០០៤-២០១១ និង ២០១១-២០១៦

| | ១៩៩៩-២០០៤ | ២០០៤-២០១១ | ២០១១-២០១៦ |
|---|---|---|---|
| **ថ្នាក់ខេត្ត** | ២២.៣៣% | ២៣.៨០% | ២៥.៧០% |
| **ថ្នាក់សង្កាត់** | ២០.១២% | ២២.៩៤% | ២៤.៦២% |
| **ថ្នាក់ឃុំ** | ១៦.១០% | ១៩.៥៣% | ២៧.៧១% |

*ប្រភព: Jean Munro, (2012). ភាពជាតំណាងរបស់ស្ត្រីក្នុងថ្នាក់ដឹកនាំនៅប្រទេសវៀតណាម. UNDP*